ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០៤៧......សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី២៦ខែសីហា ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសបេក្ខជន ចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជនចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជូនដំណឹងដល់បេក្ខជនទាំងពីរភេទ ដែលត្រូវប្រឡងប្រជែងនៅមណ្ឌលប្រឡងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ តាមកាលបរិច្ឆេទ និងពេលវេលាកំណត់ដូចខាងក្រោម÷

១. សម័យប្រឡង នៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៦

- ម៉ោង ៧:១៥ - ៨:០០ : ស្តែនម្រាមដៃ ពិនិត្យវត្តមាន ប្រកាសបទបញ្ញត្តិ និងចែកសន្លឹកកិច្ចការដល់បេក្ខជន
- ម៉ោង ៨:០០ - ៩:៣០ : វិញ្ញាសា ពន្ធដារ
- ម៉ោង ៩:៤៥ - ១១:១៥ : វិញ្ញាសា គណនេយ្យ
- ម៉ោង ១២:៤៥ - ១:៣០ : ស្តែនម្រាមដៃ ពិនិត្យវត្តមាន ប្រកាសបទបញ្ញត្តិ និងចែកសន្លឹកកិច្ចការដល់បេក្ខជន
- ម៉ោង ១:៣០ - ៣:០០ : វិញ្ញាសា សេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- ម៉ោង ៣:១៥ - ៤:៤៥ : វិញ្ញាសា កុំព្យូទ័រ និងភាសាអង់គ្លេស

២. បញ្ជីរាយនាមបេក្ខជន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីចូលរួមប្រឡងនឹងមានបិទផ្សាយនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារ ឬសាលាជាតិពន្ធដារ និងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬបេក្ខជនអាចទទួលព័ត៌មាននៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh និងគេហទំព័រនាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ចនិងហិញ្ញវត្ថុ www.pd.mef.gov.kh ឬគេហទំព័រវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ www.efi.mef.gov.kh ចាប់ពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ តទៅ ។

៣. ប្លង់មណ្ឌលប្រឡង បញ្ជីរាយនាមបេក្ខជនតាមបន្ទប់ លេខតុ និង Barcode នឹងត្រូវបិទផ្សាយនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៦ ចាប់ពីវេលាម៉ោង ៨:០០ នាទីព្រឹក ។

Collection by VCAT Professional Consultant

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, COMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបេក្ខជន ដែលមានឈ្មោះចូលរួមប្រឡង ត្រូវត្រៀមលក្ខណៈជាមុននូវឯកសារដូចជា សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណ ឬប័ណ្ណសម្គាល់និស្សិត ឬប័ណ្ណមន្ត្រីរាជការជាដើម ។

**បញ្ជាក់:** គណៈកម្មការរៀបចំការប្រឡង រក្សាសិទ្ធិក្នុងការកែប្រែសេចក្ដីជូនដំណឹងនេះក្នុងករណីចាំបាច់ ។

**រដ្ឋលេខាធិការ**

**ប្រធានគណៈកម្មការប្រឡង**

បណ្ឌិត ហ៊ាន សាហ៊ីប

**ចម្លងជូន÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ

“ដើម្បីជូនជ្រាប”

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
- វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- នាយកដ្ឋានបុគ្គលិក នៃគសហវ

“ សូមមេត្តាជួយផ្សព្វផ្សាយ ”

- ឯកសារ-កាលប្បវត្តិ

Collection by VCAT Professional Consultant